**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ០១ សណន**

# សេចក្តីណែនាំ
# ស្តីពី
# ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានកំណត់ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជនឱ្យកាន់តែប្រសើរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលក្នុងនោះរួមមាន ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ នៅក្នុងកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា (**គ.វ.រ**) កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិបានណែនាំដល់ក្រសួង ស្ថាប័នឱ្យធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីធានាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានប្រសិទ្ធភាពខ្ពស់។

ជាការកត់សម្គាល់ ក្រសួង ស្ថាប័នមួយចំនួនបាននិងកំពុងធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធ ដែលឈានដល់ការកាត់បន្ថយ ការកែសម្រួល ការច្របាច់បញ្ចូលគ្នា ឬការលុបចោលមុខងារ និងអង្គភាពមួយចំនួនក្រោមឱវាទរបស់ខ្លួន។ ដើម្បីជំរុញបន្ថែមដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធានាបាននូវសង្គតិភាពនៃដំណើរការនេះ រាជរដ្ឋាភិបាលសូមណែនាំដល់ក្រសួង ស្ថាប័នក្នុងក្របខណ្ឌនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ដូចខាងក្រោម៖

## ១. គោលបំណង

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នមានគោលបំណងលើកកម្ពស់ដំណើរការនៃក្រសួង ស្ថាប័នឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងក្របខណ្ឌនៃការបំពេញមុខងារនិងបេសកកម្មរបស់ខ្លួន ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បី៖

- ធានាបានថាមុខងាររបស់ក្រសួង ស្ថាប័នត្រូវបានអនុវត្តដោយត្រឹមត្រូវនិងសមស្របគាំទ្រដល់ការសម្រេចគោលបំណងនៃបេសកកម្មរបស់ក្រសួង ស្ថាប័ន
- វាយតម្លៃសមត្ថភាពគន្លឹះដែលចាំបាច់របស់ក្រសួង ស្ថាប័ន និងវិសាលភាពនៃការងារដែលត្រូវអនុវត្តដើម្បីគាំទ្រការលើកកម្ពស់សមត្ថភាពនេះ
- ពិនិត្យឡើងវិញតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងដែនកំណត់នៃសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- វាយតម្លៃប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលបានឬនឹងត្រូវបំពេញ
- ពិនិត្យឡើងវិញជម្រើសទាំងឡាយនៃការផ្តល់សេវា និងធានាថាសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលត្រូវអនុវត្តមានលក្ខណៈសមស្របជាមួយជម្រើសនោះ
- ធានាថាសកម្មភាពនិងធនធានរបស់ក្រសួង ស្ថាប័ន ដែលត្រូវប្រើប្រាស់ឆ្លើយតបនឹងគោលបំណងនៃសេវា និងអ្នកប្រើប្រាស់សេវា។

## ២. ភាពចាំបាច់នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន គឺដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមមួយចំនួនដែលក្រសួង ស្ថាប័នបាននិងកំពុងជួបប្រទះ រួមមាន៖

- ភាពមិនច្បាស់លាស់ឬការត្រួតជាន់គ្នានៃមុខងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ភាពខ្វះចន្លោះនៃការធ្វើអាទិភាវូបនីយកម្ម និងការផ្តោតលើសកម្មភាពដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់ ឈរលើមូលដ្ឋាននៃធនធានថវិកានិងមនុស្សរបស់ក្រសួង ស្ថាប័ន
- ភាពស្មុគស្មាញនិងបញ្ហាលំបាកនៅក្នុងអន្តរទំនាក់ទំនងរវាងក្រសួង ស្ថាប័ន និងក្រសួង ស្ថាប័ន ឬរវាងអង្គភាពនិងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នតែមួយ
- បញ្ហាអសង្គតិភាពឬភាពមិនរលូននិងប្រទាក់ក្រឡានៃការកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល វិស័យ ឬរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- បណ្តឹងតវ៉ាឬការមិនពេញចិត្តពីភាគីពាក់ព័ន្ធឬអ្នកប្រើប្រាស់សេវា ចំពោះកម្រិតគុណភាពនៃសេវាដែលផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ផលប៉ះពាល់នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មី ក្នុងការអនុវត្តមុខងារ និងសកម្មភាពការងារទាំងឡាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

## ៣. គោលដៅនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ប្រឈមនឹងបញ្ហាខាងលើ ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធមានគោលដៅចម្បងគឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការចំណាយថវិកា ការប្រើប្រាស់ធនធានមនុស្ស និងការងាររាជរដ្ឋាភិបាល នៅក្នុងការអនុវត្តមុខងារនិងបេសកកម្មរបស់ក្រសួង ស្ថាប័ន។ លទ្ធផលនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធនឹងអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អាចកំណត់បាននូវ៖

- មុខងារនិងរចនាសម្ព័ន្ធថ្មី ដែលសមស្របនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងរបស់វិស័យនីមួយៗ
- ការចាត់ចែងប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងការអនុវត្តមុខងារ
- ការគ្រប់គ្រងនិងចាត់ចែងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដោយកំណត់បានពិតប្រាកដនូវតម្រូវការធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រី និងការពង្រាយមន្ត្រី
- សមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ដែលមានភាពច្បាស់លាស់ អាចត្រួតពិនិត្យនិងវាយតម្លៃបាន ព្រមទាំងមានភាពកាន់តែប្រសើរ។

## ៤. គោលការណ៍ទូទៅ

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធត្រូវអនុវត្តដោយក្រសួង ស្ថាប័នសាមីនិងត្រូវផ្អែកលើគោលការណ៍ទូទៅ ដូចខាងក្រោម៖

- ការធានានូវការសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៧ នៃរដ្ឋសភា
- ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ផ្អែកលើអភិក្រមជាភាពនៃប្រព័ន្ធតួអង្គតែមួយ
- ភាពជាម្ចាស់ ស្មារតីទទួលខុសត្រូវ និងនវានុវត្តន៍របស់ក្រសួង ស្ថាប័ន
- ប្រសិទ្ធភាពខ្ពស់នៃដំណើរការរដ្ឋបាលសាធារណៈ ដោយមានការកំណត់មុខងារនិងរចនាសម្ព័ន្ធ ការប្រើប្រាស់ធនធានមនុស្ស ថវិកា និងបច្ចេកវិទ្យាសមស្របនិងចំគោលដៅ ដើម្បីសម្រេចបានសមិទ្ធកម្មកាន់តែប្រសើរ សម្រាប់ប្រជាជន
- ការរក្សាប្រយោជន៍មន្ត្រីពាក់ព័ន្ធនឹងអង្គវិជ្ជាជីវៈ ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ បៀវត្ស និងប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងករណីមានការកែសម្រួលមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន។

## ៥. វិសាលភាពនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ត្រូវរៀបចំនិងអនុវត្តសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។

## ៦. ក្របខណ្ឌពេលវេលាអនុវត្ត

ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នជាលក្ខណៈរួមឱ្យបានរួចរាល់ ក្នុងឆមាសទី១ នៃឆ្នាំ២០២៤ ដោយកំណត់ឱ្យបានច្បាស់លាស់នូវមុខងារនិងរចនាសម្ព័ន្ធ ព្រមទាំងតម្រូវការសមស្របនៃការប្រើប្រាស់ធនធានមនុស្សនិងថវិកា ដែលធានាថាមុខងារនិងបេសកកម្មរបស់ក្រសួង ស្ថាប័ននឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ នៅដំណាក់កាលបន្ទាប់ ក្រសួង ស្ថាប័នត្រូវបន្តការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នដោយផ្តោតលើមុខងារស្នូលដែលជាមុខងារមានលក្ខណៈគាំទ្រទូទៅរបស់អង្គភាពនៃក្រសួង ស្ថាប័ន និងមុខងារជំនាញរបស់អង្គភាពនៃក្រសួង ស្ថាប័ន ផ្អែកលើការណែនាំដោយឡែករបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

## ៧. វិធីសាស្ត្រអនុវត្ត

ក្រសួង ស្ថាប័ន ត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ដោយគិតគូរឈរលើមូលដ្ឋានដូចខាងក្រោម៖

### ៧.១ ការណែនាំសម្រាប់ការពិនិត្យឡើងវិញនិងការវិភាគមុខងារ

- ការផ្សារភ្ជាប់មុខងាររបស់ក្រសួង ស្ថាប័ន ជាមួយគោលបំណងជាយុទ្ធសាស្ត្រនិងការងារអាទិភាពជាយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាលជារួម។ ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវទីតាំងរបស់ខ្លួនក្នុងការអនុវត្តមុខងារនិងបេសកកម្ម ការផ្សារភ្ជាប់សកម្មភាពដើម្បីគាំទ្រការងារអាទិភាពជាយុទ្ធសាស្ត្រ ការស្វែងយល់អំពីនិន្នាការខាងក្រៅបញ្ហាខាងក្នុង និងការងារអាទិភាពជាយុទ្ធសាស្ត្រ
- ការពិនិត្យឡើងវិញនូវសេចក្តីត្រូវការនិងការរំពឹងទុករបស់ភាគីពាក់ព័ន្ធ ពិសេសអ្នកប្រើប្រាស់សេវា និងនិយាមសេវាផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ការពិនិត្យ ការស្វែងយល់ និងការប្រៀបធៀបជាមួយឧត្តមានុវត្តន៍ក្នុងការផ្តល់សេវាសាធារណៈដោយត្រូវគិតគូរដល់ជម្រើសទាំងឡាយ ពាក់ព័ន្ធនឹងអភិក្រមនៃការផ្តល់សេវាប្រកបដោយឧត្តមភាព
- ការវាយតម្លៃសមត្ថភាពបច្ចុប្បន្ន និងអនាគតរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលចាំបាច់ក្នុងក្របខណ្ឌនៃការអនុវត្តការងារ អភិក្រមនៃការផ្តល់សេវា ការបំពេញសមត្ថកិច្ច ការប្រើប្រាស់ឧបករណ៍ មធ្យោបាយផ្សេងៗ និងប្រព័ន្ធដំណើរការ
- ការស្វែងរកមតិយោបល់ និងការពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកំណត់នូវភាពប្រឈម ជម្រើសជាដំណោះស្រាយ និងកាលានុវត្តភាពនៃការកែលម្អដំណើរការការងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ។

### ៧.២ ក្របខណ្ឌគោលនយោបាយនិងគតិយុត្ត

ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ដោយផ្អែកលើ៖

- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាមូលដ្ឋានគោល
- គោលនយោបាយតាមវិស័យដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល
- ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែងរបស់ក្រសួង ស្ថាប័ន
- ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ៧.៣ ក្របខណ្ឌថវិកានិងធនធានមនុស្ស

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ត្រូវអនុវត្តផ្អែកលើគោលការណ៍នៃការធានានូវប្រសិទ្ធភាព ដូចខាងក្រោម៖

- ការគ្រប់គ្រងចំណាយលើបន្ទុកបុគ្គលិក ដោយត្រូវរក្សាក្នុងកម្រិតមិនឱ្យលើសពិដានចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសេចក្តីណែនាំស្តីពីហិរញ្ញវត្ថុសាធារណៈ
- ការប្រើប្រាស់ធនធានមនុស្សឱ្យចំជំនាញ ដោយមានការបែងចែកភារកិច្ចច្បាស់លាស់ មានប្រព័ន្ធគ្រប់គ្រងវត្តមាន និងសមិទ្ធកម្មការងារ។

## ៧.៤ នីតិវិធីនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នត្រូវពិនិត្យឡើងវិញមុខងាររបស់ខ្លួន ដោយធៀបជាមួយនឹងមុខងាររបស់ក្រសួង ស្ថាប័នដទៃទៀតក្នុងក្របខណ្ឌរាជរដ្ឋាភិបាលនិងវិស័យ និងការពិនិត្យឡើងវិញរចនាសម្ព័ន្ធនិងមុខងារអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នផងដែរ។ ផ្អែកលើក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធ ក្រសួង ស្ថាប័នត្រូវកំណត់និងរៀបចំបញ្ជីមុខងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទរបស់ខ្លួន ដែលមុខងារទាំងនោះ អាចត្រូវធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

**ប្រភេទ ១៖** មុខងារចាត់ទុកថាជាមុខងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលកំពុងអនុវត្តជាក់ស្តែង៖

ក. មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

ខ. មានកំណត់ក្នុងគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ តែមិនមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

គ. មិនមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ឬក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន

**ប្រភេទ២៖** មុខងារចាត់ទុកថាជាមុខងាររបស់ក្រសួង ស្ថាប័ននិងអង្គភាពក្រោមឱវាទ ប៉ុន្តែមិនបានអនុវត្តជាក់ស្តែង

ក. មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ឬកំណត់ក្នុងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន

ខ. មិនទាន់មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័ន ក្រោយពីបានរៀបចំបញ្ជីមុខងាររបស់ខ្លួន ត្រូវធ្វើការវិភាគ ដោយបែងចែកមុខងារជាបួនប្រភេទគឺ៖

ក. **មុខងារគួររក្សាទុក៖** ជាមុខងារច្បាស់លាស់ក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអង្គភាព

ខ. **មុខងារគួរមានការកែលម្អឡើងវិញ៖** ជាមុខងារដែលត្រូវមានការពិនិត្យពិភាក្សា និងសម្រេចជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដោយហេតុមានលក្ខណៈត្រួតគ្នា មិនច្បាស់លាស់ក្នុងដែនសមត្ថកិច្ចអនុវត្ត ត្រូវបានធ្វើប្រតិភូកម្មឬផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

គ. **មុខងារគួរលុបចោល៖** ជាមុខងារដែលមិនសូវសំខាន់ មិនសូវផ្តល់ប្រយោជន៍សាធារណៈ មានតម្លៃបន្ថែមទាប មានតម្រូវការតិចតួច គ្មានតម្រូវការពីអ្នកទទួលសេវា ត្រូវបានធ្វើប្រតិភូកម្មឬផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ឃ. **មុខងារគួរផ្ទេរចេញ៖** ជាមុខងារគួរផ្ទេរទៅក្រសួង ស្ថាប័នផ្សេង ឬគួរធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិ ដោយហេតុត្រួតជាន់គ្នាជាមួយក្រសួង ស្ថាប័នផ្សេង ដែលក្រសួង ស្ថាប័នផ្សេងអាចអនុវត្តដោយប្រសិទ្ធភាពជាង ឬគួរធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិព្រោះជាមុខងារផ្តល់សេវាសាធារណៈដែលនៅកៀកនឹងប្រជាពលរដ្ឋ។

## ៧.៥ ការពិគ្រោះយោបល់

ក្រសួង ស្ថាប័ន ត្រូវពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ នៅក្នុងដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ។

## ៧.៦ ការកែសម្រួលមុខងារនិងរចនាសម្ព័ន្ធ

ក្រោយពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរួចរាល់ ក្រសួង ស្ថាប័នត្រូវកំណត់និងសម្រេចលើការរក្សាទុកដដែល ការកែលម្អ ឬការរៀបចំរចនាសម្ព័ន្ធឡើងវិញឱ្យស្របនឹងមុខងារដែលក្រសួង ស្ថាប័នត្រូវទទួលបន្ទុក។ លើសពីនេះ ក្រសួង ស្ថាប័នត្រូវយកចិត្តទុកដាក់ក្នុងការបង្រួមបញ្ចូលគ្នា ឬលុបចោលរចនាសម្ព័ន្ធដែលមិនចាំបាច់ និងគួររៀបចំរចនាសម្ព័ន្ធថ្មីដែលមានទំហំសមស្រប។

## ៧.៧ ការរៀបចំនិងការប្រើប្រាស់ធនធានមនុស្សនិងថវិកាគាំទ្រមុខងារ

ក្រសួង ស្ថាប័នត្រូវរៀបចំនិងចាត់ចែងការប្រើប្រាស់ធនធានមនុស្សនិងថវិកាឱ្យបានត្រឹមត្រូវនិងសមស្របក្នុងក្របខណ្ឌនៃការអនុវត្តមុខងារតាមរចនាសម្ព័ន្ធនីមួយៗ ព្រមទាំងរៀបចំប្រព័ន្ធការងារឱ្យបានច្បាស់លាស់ ដើម្បីធានាថាធនធានមនុស្សនិងថវិកាដែលមានត្រូវបានចាត់ចែងនិងប្រើប្រាស់អស់លទ្ធភាពនិងសក្តានុពល ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និងមុខងាររបស់ក្រសួង ស្ថាប័ន។

## ៧.៨ នីតិវិធីបន្ទាប់ពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ក្រោយពីធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរួច ក្រសួង ស្ថាប័នត្រូវរៀបចំឯកសារជូនមកក្រសួងមុខងារសាធារណៈ ដែលជាលេខាធិការដ្ឋាននៃ គ.វ.រ ដើម្បីបូកសរុបនិងរាយការណ៍ជូនគណៈកម្មាធិការជាតិ (ផ្អែកលើតារាងគំរូមានក្នុងឧបសម្ព័ន្ធ) ដែលរួមមាន៖

- របាយការណ៍នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ
- តម្រូវការធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨
- តម្រូវការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨
- ផែនការពង្រាយមន្ត្រីរាជការក្នុង និងក្រៅក្រសួង ស្ថាប័ន។

# ៨. យន្តការស្ថាប័នដឹកនាំនិងអនុវត្ត

## ៨.១ គណៈកម្មការដឹកនាំការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

គណៈកម្មការដឹកនាំការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន នឹងត្រូវបង្កើតឡើងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញតួនាទីជួយដល់ គ.វ.រ. លើការងារដឹកនាំ សម្របសម្រួល គ្រប់គ្រង និងតម្រង់ទិសការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

## ៨.២ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកដឹកនាំនិងសម្របសម្រួលការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន អាចបង្កើតក្រុមការងារបច្ចេកទេសមួយឬច្រើនតាមការចាំបាច់ ដើម្បីសម្របសម្រួលនិងគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

## ៩. យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃគ.វ.រ ត្រូវចាត់ចែងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ដើម្បីជានាការអនុវត្ត ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសេចក្ដីណែនាំនេះ។ ទន្ទឹមនេះ ក្រសួងមុខងារសាធារណៈត្រូវរាយការណ៍ជាប្រចាំជូនគ.វ.រ. អំពីវឌ្ឍនភាព បញ្ហាប្រឈមនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងស្នើជម្រើសវិធានការសមស្រប ដើម្បីគាំទ្រនិងជំរុញកិច្ចការនេះឱ្យអនុវត្តដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ១៤ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ